# ដំណាំស្វាយ

ស្វាយគឺជាដំណាំមួយប្រភេទ មានដាំច្រើនជាងគេនៅក្នុងប្រទេសកម្ពុជាយើង ប៉ុន្តែយើងនៅមិនទាន់មានពូជស្វាយដែលអាចនាំចេញយកទៅលក់នៅក្រៅប្រទេស បាននៅឡើយទេ គឺមានត្រឹមតែស្វាយប្រភេទបែបធម្មតាជាពូជក្នុងស្រុកដែលបានដាំតៗ គ្នាជារហូតមក។ ទោះបីជាយ៉ាងណាក៏ដោយ ស្វាយដែលមាននិងផលដែលទទួលបានគឺល្មមគ្រប់គ្រាន់សម្រាប់បំពេញសេចក្តីត្រូវការនៅក្នុងស្រុកតែប៉ុណ្ណោះ។ តែសម្រាប់ប្រទេសដទៃដូចជាតៃវ៉ាន់ ហ្វីលីពីន ថៃ ម៉ិចស៊ីកូវិញ គេមានពូជស្វាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិអាចនាំចេញយកទៅលក់ នៅក្រៅប្រទេសបានប្រាក់កម្រៃច្រើនជាងការលក់នៅក្នុងស្រុក។

ក្នុងចំណោមពូជស្វាយទាំងអស់ដែលចរាចរនៅលើទីផ្សារអន្តរជាតិមានតែពូជស្វាយតៃវ៉ាន់ឈ្មោះថា "IRWIN" មួយប៉ុណ្ណោះត្រូវបានក្រុមជនអ្នកទេសចរណ៍សរសើរថា មានរសជាតិ និងគុណភាពល្អជាងស្វាយណាៗទាំងអស់ បន្ទាប់មកគឺស្វាយឈ្មោះ "Carabao" មកពីប្រទេសហ្វីលីពីនត្រូវបានគេចាត់ទុកថាជាស្វាយពូជល្អបំផុតផងដែរ។



ស្វាយហៃវ៉ាន់របស់ប្រទេសតៃវ៉ាន់



ពូជស្វាយការ៉ាបាវមកពីប្រទេសហ្វីលីពីន

ក្រៅពីស្វាយទាំងពីរពូជខាងលើនៅមានពូជស្វាយមួយទៀតដែលមានប្រភពមកពីប្រទេសឥណ្ឌាគឺពូជស្វាយ "Kesar" (កេសរ) ស្វាយប្រភេទនេះត្រូវបានគេយកទៅដាំនៅច្រើនប្រទេស, ប៉ុន្តែឥណ្ឌានៅរក្សាបានជាប្រទេសនាំស្វាយនេះចេញធំជាងគេដដែល។ ក្នុងពេលថ្មីៗនេះពូជស្វាយប្រភេទ "កេសរ" នេះត្រូវបាននាំយកទៅឡង់សេនៅប្រទេសអាមេរិកទទួលបានការចាប់អារម្មណ៍ច្រើនពីសំណាក់អូតែល រីស្សត និង ភោជនីយដ្ឋានធំៗ ធ្វើឲ្យឥណ្ឌារីកមុខប៉ុនគ្រាប់ដី។



ដីនៅប្រទេសកម្ពុជាយើង អាកាសធាតុនៅក្នុងប្រទេសកម្ពុជាយើងវាអំណោយផលល្អណាស់សំរាប់ដំណាំស្វាយ ប៉ុន្តែអ្វីដែលយើងខ្វះនោះគឺពូជស្វាយមួយល្អនិងបច្ចេកទេសនៃការដាំវា ចំពោះទីផ្សារវិញគឺមិនខ្វះទេឲ្យតែយើងមានពូជស្វាយមួយដែលទីផ្សារអន្តរជាតិគេស្គាល់រួចហើយ, តែចំពោះស្វាយដែលយើងមានក្នុងប្រទេសយើងរួចហើយដូចជា កែវចិន កែវសារី កែវរមៀត វាមិនមានទីផ្សារនៅខាងក្រៅទេ។

តួយ៉ាងស្វាយ "កែវចិន" ដែលជាប្រភេទស្វាយលេខមួយក្នុងស្រុកយើង នាពេលខ្លះតម្លៃរបស់វាឡើងដល់ ៥០០០០ ទៅ ៨០០០០រៀល សម្រាប់ផ្លែមួយឡូ (១២ផ្លែ) នៅមិនទាន់បានយកទៅប្រៀបធៀបជាមួយស្វាយរបស់ស្រុកគេនៅឡើយថាតើ ស្វាយកែវចិននេះមានចំណាត់ថ្នាក់សម្រាប់នាំចេញបានដែរឬទេ?

អ្វីដែលគួរឲ្យសោកស្តាយជាងគេនោះគឺភាគច្រើនអ្នកដាំស្វាយនិយមចូលចិត្តនាំគ្នាដាំស្វាយពូជកែវរមៀតច្រើនជាងគេ ព្រោះវាប្រើពេលត្រឹមតែ ៣ឆ្នាំអាចទទួលបានផល តែតម្លៃរបស់វាថោកពិបាកលក់ចេញ និងជួបប្រទះបញ្ហាដូងស៊ីដើមច្រើន ធ្វើឲ្យអ្នកដាំស្វាយប្រភេទនេះខកចិត្តច្រើនគ្នាណាស់។

ដើម្បីទទួលបានកម្រៃខ្លះពីការដាំយើងគួរនាំគ្នារើសពូជស្វាយដែលមានគុណភាពល្អមកដាំ ដូចជាស្វាយកែវចិន ស្វាយទុរេន ព្រោះវាមានរសជាតិឆ្ងាញ់មានតម្លៃខ្ពស់ក្នុងទីផ្សារនិងងាយលក់ចេញក្នុងទីផ្សារ។



កន្លងមកនេះក្រុមហ៊ុនម៉ុងឫទ្ធីក្រុបទើបបាននាំចូលពូជស្វាយ "ហៃវ៉ាន់" គឺពូជស្វាយ "IRWIN" មកដាំនៅដីចំការរបស់ក្រុមហ៊ុននៅកែវផុស និងបានប្រាប់ឲ្យដឹងថាស្វាយពូជហៃវ៉ាន់នេះមានតម្លៃខ្ពស់ណាស់នៅទីផ្សារប្រទេសកូរ៉េ ជប៉ុន និងហុងកុង។ ក្នុងស្វាយមួយដើមអាចផ្តល់កម្រៃជាចំណូលបានរហូតដល់ ៥០០ដុល្លារក្នុង១ឆ្នាំ ប្រើពេលត្រឹមតែប្រាំបីខែប៉ុណ្ណោះនឹងទទួលបានផលពីវា ដើមវាត្រូវបានតម្រឹមឲ្យនៅទាបៗ ងាយស្រួលគ្រប់គ្រងនិងថែរក្សា។ តាមព័ត៌មានមួយចំនួនដែលយើងទទួលបានតាមរយៈទូរស័ព្ទទៅសាកសួរផ្ទាល់ ជាពិសេសគឺអ្នកដាំផ្ទាល់របស់ក្រុមហ៊ុនម៉ុងឫទ្ធីនៅចំការឯកែវផុសបានឲ្យដឹងថា អ្នកដែលមានបំណងចង់ដាំអាចទាក់ទងទៅផ្នែកដាំស្វាយនេះនៅឯចំការកែវផុស ប៉ុន្តែមានការតម្រូវមួយគឺអ្នកចង់បានពូជស្វាយនេះទៅដាំ ត្រូវដាំស្វាយណាមួយនៅលើដីត្រូវដាំឲ្យហើយជាស្រេចរហូតវាដុះបានទំហំដើមប៉ុនមេដៃ មេជើងសិនទើបខាងក្រុមហ៊ុនអាចបង្កាត់ពូជស្វាយហៃណាំនេះឲ្យ, បុគ្គលិកបច្ចេកទេសរបស់ក្រុមហ៊ុននឹងទៅបង្កាត់ឲ្យដល់ទីកន្លែងតែម្តងបើសិនជាប្រធានគ្រប់គ្រងអនុញ្ញាតឲ្យទៅ? យើងខ្ញុំបានសាកសួរដើម្បីទិញមែកផ្សាំឬកូនភ្ជូលដែរតែតំណាងខាងផ្នែកដាំថាមិនមាន, យើងខ្ញុំបានសួរពីតម្លៃនៃការបង្កាត់នោះក៏មិនបានទទួលចម្លើយតបវិញ។ បើយោងតាមការអំពាវនាវរបស់លោកឧកញ៉ា ម៉ុងឫទ្ធី កាលពីដើមឆ្នាំកន្លងទៅនេះបានបញ្ជាក់យ៉ាងច្បាស់ថា លោកចង់ឲ្យប្រជាពលរដ្ឋខ្មែរចូលរួមដាំពូជស្វាយហៃណាំនេះឲ្យបានច្រើន លោកធានាទទួលទិញយកទាំងអស់ដើម្បីនាំចេញទៅប្រទេសកូរ៉េ, លោកឧកញ៉ាម៉ុងឫទ្ធីថែមទាំងបានបញ្ជាក់ទៀតថា បញ្ហាពូជនិងបច្ចេកទេស គឺខាងលោកជាអ្នកផ្តល់ឲ្យ ត្រង់នេះវាហាក់ដូចជាមានភាពស្មុគស្មាញបន្តិច ព្រោះវាជារឿងពិបាកសម្រាប់អ្នកចង់ដាំដោយហេតុថា អ្នកនោះឯងត្រូវមានកូនស្វាយដាំរួចជាមុនសិន មិនអាចទិញពូជស្វាយនោះស្រាប់ៗមកដាំបាន ឯតម្លៃនោះទៀតសោតក៏មិនដឹង។

តែទោះជាយ៉ាងណាក៏ដោយចុះ ចាត់ទុកថានេះជាលើកទីមួយហើយដែលក្រុមហ៊ុនបាននាំចូលពូជស្វាយលេខមួយក្នុងទីផ្សារអន្តរជាតិមកដាំនៅក្នុងស្រុក និងមានបំណងចែកចាយឲ្យដល់ប្រជាពលរដ្ឋខ្មែរផ្សេងទៀតបានដាំដែរ។



សម្រាប់អ្នកដែលមានបំណងចង់ដាំពូជស្វាយ "ហៃវ៉ាន់" នេះអាចទាក់ទងទៅក្រុមហ៊ុនម៉ុងឫទ្ធីដោយផ្ទាល់ គឺទាក់ទងប្រធានផ្នែកចំការស្វាយនោះតែម្តង និងអ្នកបច្ចេកទេសខាងផ្នែកដាំដើម្បីទទួលបានព័ត៌មានបន្ថែមស្តីពីពូជស្វាយនេះតាមរយៈលេខទូរស័ព្ទ: ០១៦ ៣០០ ០៩៧ និង ០១៦ ៦០៧ ២៧៩។



ដើម្បីឲ្យស្វាយចេញផ្លែបានច្រើន អ្នកដាំចាំបាច់ណាស់ត្រូវកាត់តម្រឹមមែករបស់វាឲ្យនៅតិចបំផុតតាមដែលអាចធ្វើទៅបាន។

នៅប្រទេសចិន, ដើមស្វាយបន្ទាប់ពីបានផលរួច គេកាត់ត្រួយស្វាយចោលទាំងអស់គ្មានសល់ស្លឹកមួយសន្លឹកណាទេ។

គេធ្វើបែបនេះដើម្បីបន្ថយការដុះលូតលាស់មែកនិងស្លឹកនិងបង្ខំឲ្យស្វាយចេញជា ផ្កា ផ្លែ ជាជាងយកជីជាតិដែលវាស្រូបបានទៅចិញ្ចឹមស្លឹកនិងមែក។

មែកស្វាយណាដែលដុះត្រង់ទៅលើត្រូវតែកាត់ចោល ដើម្បីឲ្យវាបែកមែកមកខាងៗជាជំនួស ព្រោះបើទុកវាឲ្យដុះលូតលាស់ទៅលើវាបានត្រឹមតែល្អដើម និងចេញផ្កា តែគ្មានផ្លែទេព្រោះអ្វីៗទាំងអស់ត្រូវយកទៅចិញ្ចឹមមែកនោះឲ្យខ្ពស់ទៅលើ តែមិនបានប្រយោជន៍អ្វីទាំងអស់ដល់ការចេញផ្លែ។



ការរក្សាកម្ពស់ស្វាយឲ្យនៅទាបត្រឹមតែ ២ម៉ែត្រ គឺជាការចាំបាច់ណាស់ដើម្បីឲ្យយើងងាយស្រួលគ្រប់គ្រងទៅលើការលូតលាស់របស់វា, មួយវិញទៀតនោះគឺផ្តល់លទ្ធភាពឲ្យផ្លែរបស់វាមានទំហំល្អ ព្រោះដើម

របស់វាត្រូវក្រិន ម្លោះហើយសារធាតុចិញ្ចឹមភាគច្រើននិងផ្តល់ទៅឲ្យផ្លែជាជាងផ្តល់ឲ្យស្លឹកនិងបំពង់ខ្ចីៗ។ នៅចំការស្វាយធំៗគេប្រើម៉ាស៊ីនធំៗ កាត់តម្រឹមមែកស្វាយទាំងសងខាងនិងមែកដែលដុះបែកទៅលើឲ្យនៅត្រឹមកម្ពស់មួយដែលគេចង់បាន។

នៅប្រទេសកម្ពុជាយើងកម្រមានអ្នកកាត់តម្រឹមមែកស្វាយឲ្យនៅទាបណាស់គឺគេទុកបណ្តោយឲ្យវាដុះតាមអំពើចិត្ត រហូតមានដើមធំៗលែងអាចគ្រប់គ្រងបាន។

ដើម្បីទទួលប្រាក់ចំណូលបានច្រើន អ្នកដាំស្វាយគួរងាកមកជ្រើសរើសពូជស្វាយដែលមានគុណភាពល្អ មានតម្លៃក្នុងទីផ្សារ បើជាពូជស្វាយដែលអាចនាំចេញបានផងនោះរឹតតែប្រសើរ ចៀសវាងដាំស្វាយដែលទទួលបានផលហើយតែមិនអាចលក់ចេញបានឬលក់បានដែរ តែបានចំណូលតិចតួចមិនសមល្មមសម្រាប់ធៀបជាមួយការចំណាយ។




ប្រទេសហ្វីលីពិនប្រឹងប្រែងខ្លាំងណាស់ដើម្បីឡង់សេស្វាយរបស់ខ្លួនលើទីផ្សារអន្តរជាតិ ឥណ្ឌាក៏ប្រឹងប្រែងខ្លាំងណាស់ដែររហូតមន្ត្រីធំៗរបស់ឥណ្ឌាស្តាយផ្លែស្វាយទៅឡង់សេដល់អាមេរិក ព្រោះគេគិតថាវាជាទីផ្សារមួយយ៉ាងធំសម្រាប់គេ។

ចំណែកខាងប្រទេសអាហ្វ្រិកវិញ មិនបានល្បីដោយសារផ្លែស្វាយផ្អែមដូចប្រទេសដទៃឡើយ តែបែរជាល្បីខ្លាំងជាមួយគ្រាប់ស្វាយទៅវិញព្រោះមានស្វាយមួយប្រភេទ មើលទៅដូចស្វាយដទៃឯទៀតដែរ តែគ្រាប់វាមានគុណសម្បត្តិអាចបញ្ចុះទម្ងន់បានយ៉ាងមានប្រសិទ្ធភាព ធ្វើឲ្យអ្នកដាំស្វាយនៅប្រទេសមួយចំនួនខាងអាហ្វ្រិកពង្រីកផ្ទៃដី ដាំស្វាយច្រើនជាងមុន ដើម្បីយកគ្រាប់លក់ឲ្យទៅក្រុមហ៊ុនកែច្នៃនៅអាមេរិកផ្សំធ្វើជា ថ្នាំបញ្ចុះទម្ងន់។

ស្វាយភាគច្រើនដែលនាំចូលទៅអាមេរិកគឺចេញមកពីប្រទេសម៉ិចស៊ិក្វ។ ស្វាយលើទីផ្សារអន្តរជាតិផ្សេងទៀតក៏ត្រូវបាននាំចូលទៅអាមេរិកដែរ តែប្រទេសម៉ិចស៊ិក្វជាអ្នកប្រមូលនាំចូលរួមជាមួយការដាំក្នុងស្រុកបន្ថែម។

ប្រទេសតៃវ៉ាន់បាននាំយកស្រីស្អាតៗទៅឡង់សេបង្ហាញស្វាយរបស់ខ្លួននៅប្រទេសជប៉ុន ទោះបីជានៅជប៉ុនគេចូលចិត្តស្វាយរបស់តៃវ៉ាន់រួចទៅហើយក្តី តែគេនៅតែបន្តឡង់សេស្វាយគេស្ទើរតែរាល់ឆ្នាំ ដើម្បីដាស់តឿនអ្នកបរិភោគឲ្យស្រលាញ់ស្វាយគេកុំបែកចិត្តទៅភ្លក្សស្វាយណាផ្សេងទៀតនាំឲ្យគេបាត់បង់ទីផ្សារ៕

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)